# ការសម្រេចចិត្តរបស់អ្នកដើម្បីបំរើព្រះ

***តើអ្នកត្រូវតែធ្វើយ៉ាងណាខ្លះ ដើម្បីឲ្យបានក្លាយជាមិត្តនៃព្រះ? (១, ២)***

***តើអ្នកឧទ្ទិសថ្វាយខ្លួនរបស់អ្នកដល់ព្រះយ៉ាងដូចម្តេច? (១)***

***តើអ្នកគួរធ្វើបុណ្យជ្រមុជទឹកនៅពេលណា? (២)***

***តើអ្នកអាចទទួលកម្លាំងយ៉ាងដូចម្តេច ដើម្បីជួយអ្នកឲ្យនៅស្មោះត្រង់ចំពោះព្រះជានិច្ច? (៣)***

១. ដើម្បីក្លាយជាមិត្តនៃព្រះ អ្នកត្រូវតែទទួលចំណេះត្រឹមត្រូវអំពីសេចក្ដីពិតខាងព្រះគម្ពីរ (ធីម៉ូថេទី១ ២:៣, ៤) មានជំនឿលើអ្វីដែលអ្នកបានរៀន (ហេព្រើរ ១១:៦) ប្រែចិត្តពីបាបរបស់អ្នក (កិច្ចការ ១៧:៣០, ៣១) ហើយកែប្រែជីវិតរបស់អ្នកជាថ្មីឡើងវិញ (កិច្ចការ ៣:១៩) បន្ទាប់មក សេចក្ដីស្រឡាញ់របស់អ្នកចំពោះព្រះនឹងជំរុញឲ្យអ្នកឧទ្ទិសថ្វាយខ្លួនដល់ទ្រង់ ។ នេះមានសេចក្ដីថា ក្នុងសេចក្ដីអធិស្ឋានផ្ទាល់ខ្លួនដល់ព្រះ អ្នកទូលប្រាប់ទ្រង់ ថាអ្នកប្រគល់ខ្លួនដល់ទ្រង់ដើម្បីធ្វើតាមព្រះហឫទ័យនៃទ្រង់ ។—ម៉ាកុស ១៦:២៨; ២២:៣៧

២. ក្រោយពេលអ្នកបានឧទ្ទិសថ្វាយខ្លួនដល់ព្រះហើយ នោះអ្នកគួរតែធ្វើបុណ្យជ្រមុជទឹក ។ (ម៉ាថាយ ២៨:១៩, ២០) ពិធីបុណ្យជ្រមុជទឹកគឺបង្ហាញឲ្យមនុស្សរាល់គ្នាដឹង ថាអ្នកបានឧទ្ទិសថ្វាយខ្លួនដល់ព្រះយេហូវ៉ា ។ ដូច្នេះ ពិធីបុណ្យជ្រមុជទឹកគឺសំរាប់តែពួកអ្នកដែលពេញវ័យគ្រប់គ្រាន់នឹងសម្រេចចិត្តបំរើព្រះ ។ ពេលបុគ្គលម្នាក់ទទួលបុណ្យជ្រមុជទឹក នោះរូបកាយទាំងមូលរបស់គាត់គួរត្រូវពន្លិចទៅក្នុងទឹកមួយភ្លែត ។*—ម៉ាកុស ១:៩, ១០; កិច្ចការ ៨:៣៦

៣. ក្រោយពេលអ្នកបានឧទ្ទិសថ្វាយខ្លួនហើយ នោះព្រះយេហូវ៉ាទ្រង់នឹងតម្រូវឲ្យអ្នកធ្វើតាមសេចក្ដីសន្យារបស់អ្នក ។ (ទំនុកដំកើង ៥០:១៤; សាស្ដា ៥:៤, ៥) អារក្សនឹងខំរកឃាត់ឃាំងមិនឲ្យអ្នកបំរើព្រះយេហូវ៉ា ។ (ពេត្រុសទី១ ៥:៨) ប៉ុន្តែសូមចូលទៅជិតព្រះដោយសេចក្ដីអធិស្ឋាន ។ (ភីលីព ៤:៦, ៧) សូមសិក្សាបន្ទូលរបស់ទ្រង់ជារៀងរាល់ថ្ងៃ ។ (ទំនុកដំកើង ១:១-៣) សូមនៅជិតស្និទ្ធនឹងក្រុមជំនុំផង ។ (ហេព្រើរ ១៣:១៧) ដោយធ្វើរបស់ទាំងនេះ អ្នកនឹងទទួលកម្លាំងឲ្យនៅស្មោះត្រង់ចំពោះព្រះជានិច្ច ។ ត្រូវហើយ ដោយហេតុដូច្នេះអ្នកនឹងអាចធ្វើតាមសេចក្ដីដែលព្រះតម្រូវពីអ្នករហូតដល់អស់កល្បជានិច្ច!





---

* ការសិក្សាសៀវភៅ *Knowledge That Leads to Everlasting Life* ឬសៀវភៅស្រដៀងគ្នាឯទៀត ដែលបោះពុម្ពដោយសមាគមប៉មយាមខាងព្រះគម្ពីរនិងខិត្តប័ណ្ណ គឺជាការប្រសើរដើម្បីរៀបចំខ្លួនសំរាប់ពិធីបុណ្យជ្រមុជទឹក ។